**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** | **ក្រសួងសុខាភិបាល**

លេខ: ០៤៥៥/២១ ក.ប/ស.ណ.ន.ខ.វ

# សេចក្តីណែនាំរួម

## ស្តីពី

## លក្ខណវិនិច្ឆ័យក្នុងការផ្អាក និងបើកឡើងវិញ នូវសកម្មភាពអាជីវកម្ម/ផលិតកម្ម ដោយវិធានការរដ្ឋបាល ដើម្បីទប់ស្កាត់ការរាលដាលជំងឺកូវីដ-១៩ និងវិធានការចាំបាច់ពេលបើកដំណើរការឡើងវិញ

យោងសេចក្តីណែនាំលេខ០៣ សណន ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២១ ស្តីពីការពង្រឹងការអនុវត្តវិធានការចាំបាច់មួយចំនួនដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ បន្ទាប់ពីរាជរដ្ឋាភិបាលបានសម្រេចបញ្ចប់ការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល និងអនុលោមតាមស្មារតី នៃកិច្ចប្រជុំរបស់គណៈកម្មការប្រឹក្សាការងារអាណត្តិទី១០ លើកទី១ កាលពីថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២១ ក៏ដូចជាក្នុងគោលបំណងធានាឱ្យបាននូវសុខុមាលភាព សុវត្ថិភាព និងជីវភាពរបស់កម្មករនិយោជិត និរន្តរភាពនៃផលិតកម្ម និងភាពអាចព្យាករណ៍បាននៃការផ្គត់ផ្គង់ទំនិញ ព្រមទាំងចូលរួមទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ នៅក្នុងរោងចក្រ សហគ្រាស ជាពិសេសរោងចក្រផ្នែកវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប នោះក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងសុខាភិបាល សូមធ្វើការណែនាំរួមដល់រដ្ឋបាលរាជធានី ខេត្ត ស្ថាប័នពាក់ព័ន្ធ ម្ចាស់ឬនាយករោងចក្រ សហគ្រាស និងកម្មករនិយោជិត ដូចខាងក្រោម៖

### ក. ការផ្អាកនិងបើកសកម្មភាពអាជីវកម្ម/ផលិតកម្មដោយវិធានការរដ្ឋបាល

#### ក.១. សិទ្ធិនៃការផ្អាក និងបើកឡើងវិញនូវសកម្មភាពអាជីវកម្ម/ផលិតកម្ម

ក្នុងករណីរកឃើញមានករណីវិជ្ជមានកូវីដ-១៩ ក្នុងរោងចក្រ សហគ្រាសណាមួយ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត អាចផ្អាកជាបណ្តោះអាសន្នចំនួន ២ថ្ងៃ នូវសកម្មភាពអាជីវកម្ម/ផលិតកម្មរបស់រោងចក្រ សហគ្រាសនោះ ឬផ្នែកខ្លះនៃរោងចក្រ សហគ្រាសនោះ ដើម្បីអនុវត្តវិធានការសុខាភិបាល និងចាត់មន្ត្រីសុខាភិបាលចុះយកសំណាក និងដើម្បីក្រុមការងារបច្ចេកទេសចម្រុះចុះពិនិត្យវាយតម្លៃអំពីកម្រិតហានិភ័យ និងកំណត់រយៈពេលនៃការផ្អាកសកម្មភាពអាជីវកម្ម/ផលិតកម្មរបស់រោងចក្រ សហគ្រាស។

ក្រោយពីផ្អាកជាបណ្តោះអាសន្នបានចំនួន ២ថ្ងៃ នូវសកម្មភាពអាជីវកម្ម/ផលិតកម្មរបស់រោងចក្រ សហគ្រាស ឬផ្នែកខ្លះនៃរោងចក្រ សហគ្រាសមួយ នោះអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ដោយយោងលើការវាយតម្លៃរបស់ក្រុមការងារបច្ចេកទេសចម្រុះ អាចសម្រេចលើការអនុញ្ញាតឱ្យបើកឡើងវិញទាំងស្រុង ឬ

បើកឡើងវិញផ្នែកខ្លះ នៃរោងចក្រ សហគ្រាសនោះ ឬត្រូវបន្តការផ្អាកសកម្មភាពអាជីវកម្ម/ផលិតកម្ម របស់រោងចក្រ សហគ្រាសនោះទាំងស្រុង ឬដោយផ្នែកខ្លះជាបន្តទៀត។

ក្រុមការងារបច្ចេកទេសចម្រុះរួមមានសមាសភាព ដូចខាងក្រោម៖

| | |
|---|---|
| - តំណាងក្រសួង ឬមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ប្រធាន |
| - តំណាងរដ្ឋបាលរាជធានី ខេត្ត ឬក្រុង ស្រុក ខណ្ឌ | អនុប្រធាន |
| - តំណាងក្រសួង ឬមន្ទីរសុខាភិបាល | អនុប្រធាន |
| - តំណាងនិយោជកនៃរោងចក្រ សហគ្រាសនីមួយៗ | សមាជិក។ |

## ក.២. រយៈពេលនៃការផ្អាកសកម្មភាពអាជីវកម្ម/ផលិតកម្ម

រោងចក្រ សហគ្រាស ឬផ្នែកខ្លះនៃរោងចក្រ សហគ្រាស អាចត្រូវបានផ្អាកសកម្មភាពអាជីវកម្ម/ផលិតកម្ម ដោយវិធានការរដ្ឋបាលរយៈពេលចំនួន ១៤ថ្ងៃ ឬតិចជាងនេះអាស្រ័យលើការវាយតម្លៃជាក់ស្តែងរបស់ក្រុមការងារបច្ចេកទេសចម្រុះ។

សហគ្រាសផ្នែកសេវាកម្ម ហិរញ្ញវត្ថុ បច្ចេកវិទ្យា និងផ្សារទំនើប, និងរោងចក្រផលិតបរិក្ខារអេឡិចត្រូនិចនិងគ្រឿងបង្គុំ, រោងចក្រដំឡើងគ្រឿងយន្ត, រោងចក្រនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស ឬក្នុងសួនឧស្សាហកម្ម, រោងចក្រដែលមានប្រើបច្ចេកទេសស្វ័យប្រវត្តិកម្មច្រើន និងមានប្រើប្រាស់កម្លាំងពលកម្មដែលមានជំនាញ និងចំណេះដឹងខ្ពស់ ព្រមទាំងរោងចក្រ សហគ្រាស ដែលមាននៅក្នុងចំណុច១១ នៃសេចក្តីណែនាំលេខ០៣ ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២១ របស់រាជរដ្ឋាភិបាលនឹងត្រូវបានផ្តល់អាទិភាពក្នុងការបង្រួមរយៈពេលដែលត្រូវផ្អាកសកម្មភាពអាជីវកម្ម/ផលិតកម្ម ដោយសារជាសេវាចាំបាច់ សារវ័ន្ត និងជារោងចក្រ សហគ្រាស ដែលជាទូទៅមានលក្ខខណ្ឌសុវត្ថិភាព និងសុខភាពការងារល្អ។

## ក.៣. លក្ខណៈវិនិច្ឆ័យនៃការផ្អាកសកម្មភាពអាជីវកម្ម/ផលិតកម្ម

រោងចក្រ សហគ្រាស ឬផ្នែកខ្លះនៃរោងចក្រ សហគ្រាស អាចត្រូវបានផ្អាកសកម្មភាពអាជីវកម្ម/ផលិតកម្ម ដោយវិធានការរដ្ឋបាលក្នុងការបង្ការជំងឺកូវីដ-១៩ ក្នុងរយៈពេលណាមួយអាស្រ័យលើការពិនិត្យវាយតម្លៃរបស់ក្រុមការងារបច្ចេកទេសចម្រុះ លើលក្ខណវិនិច្ឆ័យដូចខាងក្រោម៖

- មានករណីវិជ្ជមានកូវីដ-១៩
- មានអគារផលិតកម្ម ឬប្រតិបត្តិការតែមួយ មានភាពតូចចង្អៀត គ្មានខ្យល់ចេញ-ចូលគ្រប់គ្រាន់ដែលអាចបង្កហានិភ័យខ្ពស់ក្នុងការឆ្លងរីករាលដាលជំងឺកូវីដ-១៩
- មានសភាពធ្ងន់ធ្ងរ និងស្មុគស្មាញនៃការឆ្លងជំងឺកូវីដ-១៩ ក្នុងរោងចក្រ សហគ្រាស ដោយមិនអាចគ្រប់គ្រង និងទប់ស្កាត់ការរីករាលដាលបន្ត ជាពិសេសមិនអាចដឹងអំពីប្រភពនៃការឆ្លង និងមិនអាចញែកអ្នកដែលពាក់ព័ន្ធផ្ទាល់ និងប្រយោល
- មិនមានប្រព័ន្ធថែរក្សានិងគ្រប់គ្រងអនាម័យ សុវត្ថិភាព និងសុខភាពរបស់កម្មករនិយោជិត ជាអាទិ៍ មិនមានការបាញ់អាល់កុលលើដៃនិងដងខ្លួន, មិនមានការវាស់កម្តៅកម្មករនិយោជិតនៅពេលចូល-ចេញកន្លែងការងារ, ខ្វះកន្លែងលាងសម្អាតដៃ, មិនមានសាប៊ូឬអាល់កុលគ្រប់គ្រាន់នៅតាមកន្លែងលាងសម្អាតដៃ, មិនមានការផ្តល់ម៉ាសជូនកម្មករនិយោជិត, មិនមានការបាញ់ថ្នាំសម្លាប់មេរោគជាប្រចាំសប្តាហ៍នៅក្នុងរោងចក្រ សហគ្រាស។ល។

- មិនអាចរៀបចំឱ្យមានគម្លាតសុវត្ថិភាពបុគ្គលរវាងកម្មករនិយោជិតនៅតាមប៉ុស្តិ៍ការងារ
- មិនអាចរៀបចំឱ្យមានគម្លាតសុវត្ថិភាព និងអនាម័យល្អនៅតាមទីតាំងដែលប្រើប្រាស់រួម ដូចជា បង្គន់ ជណ្តើរ ច្រកចេញ-ចូល។ល។
- មានអាហារដ្ឋានតូចចង្អៀត មិនអាចចែកចេញជាវេនផ្សេងគ្នាបាន
- មានការដឹកជញ្ជូនកម្មករនិយោជិតចេញពីតំបន់ ដែលកំពុងផ្ទុះវិជ្ជមានកូវីដ-១៩ ឬដែលត្រូវបានវាយតម្លៃថាមានហានិភ័យខ្ពស់ក្នុងការឆ្លងរាលដាលជំងឺកូវីដ-១៩
- មានទីកន្លែងស្នាក់នៅរបស់កម្មករនិយោជិត ស្ថិតក្នុងតំបន់ដែលកំពុងផ្ទុះវិជ្ជមានកូវីដ-១៩ ឬមានហានិភ័យខ្ពស់ក្នុងការឆ្លងរាលដាលជំងឺកូវីដ-១៩
- មិនមានគ្រូពេទ្យប្រចាំរោងចក្រ ឬមិនបានចាត់តាំងឱ្យមានអ្នកគ្រប់គ្រងផ្នែកអនាម័យ សុខភាព និងសុវត្ថិភាពរបស់កម្មករនិយោជិត
- មិនផ្តល់កិច្ចសហការពេញលេញដល់ក្រុមការងារបច្ចេកទេសចម្រុះ ឬអាជ្ញាធរមានសមត្ថកិច្ចក្នុងការត្រួតពិនិត្យវាយតម្លៃ ដើម្បីកំណត់ចំនួនអ្នកប៉ះពាល់ផ្ទាល់និងប្រយោលជាមួយនឹងអ្នកមានវិជ្ជមានកូវីដ-១៩ ព្រមទាំងកម្រិតហានិភ័យនៃការឆ្លងរាលដាលបន្ត
- ខកខានមិនបានធ្វើការកែតម្រូវតាមការស្នើសុំរបស់ក្រុមការងារបច្ចេកទេសចម្រុះ ឬអាជ្ញាធរមានសមត្ថកិច្ច នូវភាពខ្វះចន្លោះនានាពាក់ព័ន្ធនឹងវិធានការអនាម័យ សុខភាព និងសុវត្ថិភាព នៅក្នុងអំឡុងពេលដាក់ឱ្យផ្អាកសកម្មភាពអាជីវកម្ម/ផលិតកម្មជាបណ្តោះអាសន្ន នា២ថ្ងៃដំបូង ។

### ក.៤. ភារកិច្ចរបស់ភាគីពាក់ព័ន្ធ

ក្នុងករណីមានវិជ្ជមានកូវីដ-១៩ នៅក្នុងរោងចក្រ សហគ្រាស ភាគីពាក់ព័ន្ធត្រូវចូលរួមអនុវត្តភារកិច្ចដូចខាងក្រោម៖

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានភារកិច្ច៖**

- សម្របសម្រួលជាមួយម្ចាស់ ឬតំណាងរោងចក្រ សហគ្រាស និងភាគីពាក់ព័ន្ធ កំណត់មុខសញ្ញាកម្មករនិយោជិតដែលពាក់ព័ន្ធដោយផ្ទាល់ និងប្រយោល ដើម្បីយកសំណាក និងធ្វើចត្តាឡីស័ក
- ទំនាក់ទំនងជាមួយម្ចាស់ ឬនាយករោងចក្រ សហគ្រាស ដើម្បីប្រមូលយកបញ្ជីឈ្មោះនិងព័ត៌មានចាំបាច់របស់កម្មករនិយោជិត
- ដឹកនាំការពិនិត្យវាយតម្លៃលើលក្ខណវិនិច្ឆ័យនានា របស់រោងចក្រ សហគ្រាស ដើម្បីកំណត់រយៈពេលត្រូវផ្អាកសកម្មភាពអាជីវកម្ម/ផលិតកម្ម ដោយវិធានការរដ្ឋបាលជាបន្តទៀត និងកាលបរិច្ឆេទ ដែលត្រូវបើកសកម្មភាពអាជីវកម្ម/ផលិតកម្មឡើងវិញ
- សម្របសម្រួលជាមួយនិយោជក និងកម្មករនិយោជិតក្នុងការផ្តល់ប្រាក់ឈ្នួលនិងអត្ថប្រយោជន៍ផ្សេងៗ ក្នុងអំឡុងពេលព្យាបាល ឬការធ្វើចត្តាឡីស័ក
- សម្របសម្រួលជាមួយរដ្ឋបាលរោងចក្រ សហគ្រាស ដើម្បីតាមដានសុខភាពនិងការអនុវត្តវិធានការសុខាភិបាលរបស់កម្មករនិយោជិតដែលត្រូវធ្វើចត្តាឡីស័ក
- ដោះស្រាយវិវាទការងារ ដែលអាចកើតឡើងជាយថាហេតុ
- សហការជាមួយនិយោជក ដើម្បីកំណត់មុខសញ្ញាកម្មករនិយោជិតដែលត្រូវយកសំណាកនៅពេលបើកដំណើរការឡើងវិញ ជាពិសេសនៅពេលដំណើរការដំបូង

- រៀបចំរបាយការណ៍ជូនអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ពិនិត្យសម្រេចលើរយៈពេលនៃការផ្អាកសកម្មភាពអាជីវកម្ម/ផលិតកម្មរបស់រោងចក្រ សហគ្រាសទាំងស្រុង ឬផ្នែកខ្លះនៃរោងចក្រ សហគ្រាស ដោយវិធានការរដ្ឋបាលជាបន្តទៀត និងកាលបរិច្ឆេទដែលអាចបើកឡើងវិញ។

**រដ្ឋបាលរាជធានី ខេត្ត មានភារកិច្ចៈ**

- សម្របសម្រួលអង្គភាពពាក់ព័ន្ធ ចុះយកសំណាកកម្មករនិយោជិត ដែលពាក់ព័ន្ធដោយផ្ទាល់ និងប្រយោល
- រក្សាសណ្តាប់ធ្នាប់ក្នុងការយកសំណាកកម្មករនិយោជិត និងបុគ្គល ដែលពាក់ព័ន្ធដោយផ្ទាល់ និងប្រយោល
- ចូលរួមពិនិត្យវាយតម្លៃលើលក្ខណវិនិច្ឆ័យរបស់រោងចក្រ សហគ្រាសដើម្បីកំណត់រយៈពេលត្រូវផ្អាកសកម្មភាពអាជីវកម្ម/ផលិតកម្មដោយវិធានការរដ្ឋបាលជាបន្តទៀត និងកាលបរិច្ឆេទដែលត្រូវបើកសកម្មភាពអាជីវកម្ម/ផលិតកម្មឡើងវិញ
- សម្របសម្រួលផ្តល់ទីតាំងសម្រាប់ការធ្វើចត្តាឡីស័ករបស់កម្មករនិយោជិត ដែលប៉ះពាល់ផ្ទាល់ជាមួយអ្នកវិជ្ជមានកូវីដ-១៩
- គ្រប់គ្រង និងតាមដានឃ្លាំមើលកម្មករនិយោជិតមានវិជ្ជមានកូវីដ-១៩ ដែលត្រូវបានដាក់ឱ្យធ្វើការព្យាបាលនៅតាមលំនៅឋាន
- គ្រប់គ្រង និងតាមដានឃ្លាំមើលកម្មករនិយោជិតដែលត្រូវបានកំណត់ឱ្យធ្វើចត្តាឡីស័កនៅតាមលំនៅឋាន
- ចូលរួមផ្តល់ការការពារសុវត្ថិភាព និងទ្រព្យសម្បត្តិរបស់រោងចក្រ សហគ្រាស ក្នុងអំឡុងពេលផ្អាកសកម្មភាពអាជីវកម្ម/ផលិតកម្មដោយវិធានការរដ្ឋបាល។

**ក្រសួងសុខាភិបាល មានភារកិច្ចៈ**

ក្រសួងសុខាភិបាលទទួលទ្រទ្រង់បច្ចេកទេស ដល់មន្ទីរសុខាភិបាលរាជធានី ខេត្ត ឱ្យបំពេញភារកិច្ចដូចខាងក្រោមៈ

- ចុះធ្វើការកំណត់មុខសញ្ញាពាក់ព័ន្ធ និងយកសំណាកកម្មករនិយោជិតនិងបុគ្គលដែលពាក់ព័ន្ធនៅទីតាំងដែលមានវិជ្ជមានកូវីដ-១៩
- ផ្តល់នូវការព្យាបាល និងអនុសាសន៍ពាក់ព័ន្ធការថែទាំសុខភាពដល់កម្មករនិយោជិតក្នុងអំឡុងពេលមានវិជ្ជមានកូវីដ-១៩
- សហការជាមួយអាជ្ញាធរមូលដ្ឋានចាត់ចែងអ្នកមានវិជ្ជមានកូវីដ-១៩ ដើម្បីដាក់ព្យាបាលនៅមន្ទីរពេទ្យ មណ្ឌលព្យាបាល ឬនៅតាមលំនៅឋាន ព្រមទាំងការដាក់ឱ្យធ្វើចត្តាឡីស័កនៅតាមមណ្ឌលសម្រាប់អ្នកប៉ះពាល់ផ្ទាល់ និងនៅតាមលំនៅឋាន សម្រាប់អ្នកប៉ះពាល់ដោយប្រយោល
- ចូលរួមពិនិត្យវាយតម្លៃលើលក្ខណវិនិច្ឆ័យរបស់រោងចក្រ សហគ្រាសដើម្បីកំណត់រយៈពេលត្រូវផ្អាកសកម្មភាពអាជីវកម្ម/ផលិតកម្មដោយវិធានការរដ្ឋបាលជាបន្តទៀត និងកាលបរិច្ឆេទដែលត្រូវបើកសកម្មភាពអាជីវកម្ម/ផលិតកម្មឡើងវិញ
- សម្របសម្រួលការចេញលិខិតបញ្ជាក់ពីការជាសះស្បើយ ឬបញ្ចប់ការធ្វើចត្តាឡីស័ក។

**និយោជក មានភារកិច្ច៖**

- ផ្តល់នូវបញ្ជីឈ្មោះនិងព័ត៌មានចាំបាច់របស់កម្មករនិយោជិតសរុបក្នុងរោងចក្រ សហគ្រាស ជាពិសេសកម្មករនិយោជិតដែលជាប់ពាក់ព័ន្ធដោយផ្ទាល់ជាមួយអ្នកមានវិជ្ជមានកូវីដ-១៩
- ផ្តល់នូវឯកសារវីដេអូកាមេរ៉ាសុវត្ថិភាព និងព័ត៌មានពាក់ព័ន្ធសម្រាប់ក្រុមការងារបច្ចេកទេស ចម្រុះធ្វើការវាយតម្លៃ និងកំណត់មុខសញ្ញាប្រភពឆ្លង អ្នកប៉ះពាល់ផ្ទាល់ និងប្រយោល និង កម្រិតហានិភ័យនៃការឆ្លងរីករាលដាលបន្ត
- ផ្តល់ទីតាំង និងកិច្ចសហការក្នុងការយកសំណាក
- ផ្តល់នូវប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗតាមការកំណត់របស់ក្រសួងការងារ និងបណ្តុះ បណ្តាលវិជ្ជាជីវៈ
- ចាត់តាំងបុគ្គលិកផ្នែករដ្ឋបាលរបស់រោងចក្រ សហគ្រាស ចំនួន ២រូប ដើម្បីទំនាក់ទំនងស្រង់ ព័ត៌មានអំពីស្ថានភាពសុខភាពកម្មករនិយោជិត ដែលត្រូវធ្វើចត្តាឡីស័កជូនមន្ត្រីពេទ្យការងារ
- ទទួលបន្ទុកចំណាយលើការធ្វើតេស្តរហ័ស (Rapid Test) បន្ថែមលើការធ្វើតេស្តដំបូងដោយ មន្ត្រីសុខាភិបាល ចំពោះកម្មករនិយោជិតដែលក្រុមការងារបច្ចេកទេសចម្រុះកំណត់ថាបាន ពាក់ព័ន្ធផ្ទាល់ជាមួយអ្នកវិជ្ជមានកូវីដ-១៩។ ការធ្វើតេស្តរហ័សនេះគឺអាចធ្វើដោយពេទ្យការងារ ឬពេទ្យរបស់មូលដ្ឋានសុខាភិបាល ដែលជាដៃគូនាយកដ្ឋានពេទ្យការងារ នៃក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- សហការជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីកំណត់មុខសញ្ញាកម្មករ និយោជិតដែលត្រូវយកសំណាក នៅពេលបើកដំណើរការឡើងវិញ។

**កម្មករនិយោជិត មានភារកិច្ច៖**

- ផ្តល់សំណាកដើម្បីវិភាគរកមេរោគកូវីដ-១៩ ដល់ក្រុមគ្រូពេទ្យ តាមការកំណត់
- ទៅព្យាបាលតាមការកំណត់របស់គ្រូពេទ្យ
- ធ្វើចត្តាឡីស័កតាមការកំណត់ និងត្រូវរាយការណ៍អំពីស្ថានភាពសុខភាពរបស់ខ្លួនជូនរដ្ឋបាល រោងចក្រ សហគ្រាស
- ត្រូវផ្តល់ព័ត៌មានបន្ទាន់ដល់រដ្ឋបាលរោងចក្រ ក្នុងករណីមានការប៉ះពាល់ផ្ទាល់ជាមួយអ្នកមាន វិជ្ជមានកូវីដ-១៩ ឬក្នុងករណីមានអាការៈសង្ស័យថាមានវិជ្ជមានកូវីដ-១៩។ ការខកខាននៃការ ផ្តល់ព័ត៌មានទាំងនេះ អាចចាត់ទុកថាបានល្មើសនឹងបទបញ្ជាផ្ទៃក្នុងរបស់រោងចក្រ សហគ្រាស និងល្មើសនឹងវិធានសុខាភិបាល
- អនុវត្តឱ្យបានខ្ជាប់ខ្ជួននូវវិធានការ "៣កុំ" និង"៣ការពារ" និង វិធានការសុខាភិបាលនានា។

## ខ. វិធានការបើកដំណើរការអាជីវកម្ម/ផលិតកម្មឡើងវិញ

អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវផ្តល់ការអនុញ្ញាតឱ្យបើកដំណើរការអាជីវកម្ម/ផលិតកម្ម របស់រោងចក្រ សហគ្រាសឡើងវិញទៅតាមកាលបរិច្ឆេទ ដែលកំណត់នៅក្នុងលិខិតផ្អាកសកម្មភាពអាជីវកម្ម/ ផលិតកម្ម ក្នុងករណីដែលកម្មករនិយោជិតនៃរោងចក្រ សហគ្រាសនោះគ្មានការផ្ទុះវិជ្ជមានកូវីដ-១៩ថ្មី ក្នុងអំឡុង ពេលនៃការផ្អាកអាជីវកម្ម/ផលិតកម្ម។

រោងចក្រ សហគ្រាស ដែលត្រូវបើកឱ្យដំណើរការអាជីវកម្ម/ផលិតកម្មឡើងវិញត្រូវអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវវិធានការសុខាភិបាល, វិធានសុវត្ថិភាព និងសុខភាពការងារ, និងវិធានការនានាដែលកំណត់ដោយអាជ្ញាធរមូលដ្ឋាន។

ដោយឡែក ចំពោះរោងចក្រផ្នែកវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប នៅខែទី១ នៃការបើកដំណើរការផលិតកម្មឡើងវិញ ត្រូវអនុវត្តវិធានការចាំបាច់ ដូចខាងក្រោម៖

១. បែងចែកកម្មករនិយោជិតចំនួន ៥០% នៃកម្មករនិយោជិតសរុប ឱ្យធ្វើការផ្លាស់វេនគ្នារៀងរាល់ ២សប្តាហ៍ម្តង ក្នុងរយៈពេល ១ខែ ដំបូងនៃការបើកដំណើរការឡើងវិញ។ ការជ្រើសរើសកម្មករនិយោជិតដែលត្រូវចូលធ្វើការវេនទី១ (២សប្តាហ៍ដំបូង) គឺត្រូវផ្តល់អាទិភាពទៅលើកម្មករនិយោជិតដែល (១) បានចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី២, (២) បានចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី១, (៣) មិនស្ថិតនៅក្នុងតំបន់ដែលតម្រូវឱ្យផ្តល់សំណាកដើម្បីវិភាគរកមេរោគកូវីដ-១៩ ឬ(៤) បានផ្តល់សំណាកដើម្បីវិភាគរកមេរោគកូវីដ-១៩ (មានលិខិតបញ្ជាក់ដោយគ្រូពេទ្យមានសមត្ថកិច្ច ឬដោយពេទ្យការងារនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ)។

២. ផ្តល់ប្រាក់ឈ្នួលចំនួន ៥០% នៃប្រាក់ឈ្នួលសុទ្ធសាធប្រចាំខែ ដែលកម្មករនិយោជិតធ្លាប់ទទួលបាននាពេលកន្លងមក ដោយរក្សាទុកនូវអត្ថប្រយោជន៍ប្រចាំខែ និងការថែមម៉ោងចំនួន ២ម៉ោង ក្នុង១ថ្ងៃ និងការថែមម៉ោងនៅថ្ងៃអាទិត្យ ។ល។ របស់កម្មករនិយោជិត។

៣. ផ្តល់ម៉ាសយ៉ាងតិចចំនួន ១ ក្នុង១ថ្ងៃ ដល់កម្មករនិយោជិត និងត្រូវណែនាំឱ្យកម្មករនិយោជិតពាក់ម៉ាសជាប្រចាំនៅកន្លែងធ្វើការងារ និងនៅពេលប្រើប្រាស់មធ្យោបាយធ្វើដំណើររួមគ្នា។

៤. រៀបចំឱ្យមានការបាញ់អាល់កុលលើដៃ និងដងខ្លួន ព្រមទាំងការវាស់កម្តៅមុនពេលចូលធ្វើការ និងក្រោយពេលអាហារថ្ងៃត្រង់។ បន្ថែមឧបករណ៍បាញ់អាល់កុលនៅក្នុងអគារផលិតកម្ម និងសាប៊ូលាងដៃនៅក្នុងបន្ទប់ទឹក។ បាញ់អាល់កុលម្តងទៀតនៅពេលចេញពីធ្វើការ ដើម្បីកាត់បន្ថយហានិភ័យនៃការឆ្លងជំងឺកូវីដ-១៩ ពេលប្រើប្រាស់មធ្យោបាយធ្វើដំណើររួមគ្នា។

៥. ត្រូវបន្តផ្តល់អាហារថ្ងៃត្រង់ដល់កម្មករនិយោជិត ប្រសិនជារោងចក្រធ្លាប់ផ្តល់មុនពេលការផ្អាកសកម្មភាពផលិតកម្មដោយវិធានការរដ្ឋបាល។ ត្រូវជូនដំណឹងឱ្យកម្មករនិយោជិតត្រូវតែយកអាហារពីលំនៅឋានរៀងៗខ្លួន ប្រសិនជារោងចក្រមិនមានផ្តល់អាហារជូនកម្មករនិយោជិត។ និយោជក ត្រូវបែងចែកវេនសម្រាប់ការបរិភោគអាហារថ្ងៃត្រង់របស់កម្មករនិយោជិតផ្សេងៗគ្នា និងត្រូវរៀបចំឃាំងរនាំងនៅតាមតុ (ប្រសិនបើអាច) ឬរៀបចំឱ្យមានគម្លាតនៅពេលអង្គុយហូបអាហារថ្ងៃត្រង់។ និយោជកគួរសម្របសម្រួលឱ្យមានការផ្គត់ផ្គង់អាហាររួមនៅក្នុងអាហារដ្ឋានរបស់ខ្លួន។

៦. រៀបចំឱ្យមានច្រកចេញ-ចូលបន្ថែម ឬបែងចែកពេលវេលា ដែលអនុញ្ញាតឱ្យកម្មករនិយោជិតដែលមកបំពេញការងារអាចចេញចូលរោងចក្រ និងទីតាំងផលិតកម្មបានដោយសុវត្ថិភាព និងមិនមានការប្រជ្រៀតគ្នា។

៧. គ្រប់គ្រងប្រព័ន្ធខ្យល់ចេញ-ចូលក្នុងទីតាំងផលិតកម្មឱ្យបានល្អ និងរៀបចំឱ្យមានការបាញ់ថ្នាំសម្លាប់មេរោគជាប្រចាំសប្តាហ៍។

៨. ជួយសម្របសម្រួលកម្មករនិយោជិត ក្នុងការចរចាជាមួយអ្នកផ្តល់សេវាដឹកជញ្ជូនកម្មករនិយោជិតឱ្យដឹកត្រឹម ៥០% នៃចំនួនដែលធ្លាប់ដឹកនាពេលកន្លងមក និងត្រូវមានអាល់កុលសម្រាប់បាញ់លាងដៃមុនពេលឡើងយានយន្ត និងលាងសម្អាតយានយន្តនៅរាល់ពេលដាក់កម្មករនិយោជិតចុះ។ កម្មករនិយោជិតត្រូវពាក់ម៉ាសជានិច្ចនៅពេលជិះរថយន្តរួមគ្នា។

៩. ផ្តល់បញ្ជីឈ្មោះកម្មករនិយោជិត (ដូចមានក្នុងបញ្ជីបើកប្រាក់ឈ្នួលប្រចាំខែមីនា) និងឈ្មោះពេទ្យ ឬគិលានុបដ្ឋាកប្រចាំរោងចក្រ តាមប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈ (https://lacms.mlvt.gov.kh/registration/upload/excel) ដើម្បីងាយស្រួលដល់ការធ្វើអន្តរាគមន៍ណាមួយក្នុងករណីចាំបាច់។

១០.រៀបចំឱ្យមានបុគ្គលិកផ្នែករដ្ឋបាលយ៉ាងតិចចំនួន ២នាក់ មកអធិការពេទ្យការងារ ដើម្បីផ្តល់ព័ត៌មានប្រចាំសប្តាហ៍អំពីការអនុវត្តវិធានការរបស់រោងចក្រ និងករណីសង្ស័យវិជ្ជមានកូវីដ-១៩ ឬការដាក់ឱ្យកម្មករនិយោជិតណាម្នាក់ធ្វើចត្តាឡីស័កនៅតាមលំនៅឋាន។

១១.បម្រុងទុកនូវឧបករណ៍ធ្វើតេស្តរហ័ស ដែលទទួលស្គាល់ដោយក្រសួងសុខាភិបាលចំនួន ១០% នៃកម្មករនិយោជិតសរុបរបស់រោងចក្រ ដើម្បីបម្រុងទុកសម្រាប់ពេទ្យការងារ ឬពេទ្យរបស់មូលដ្ឋានសុខាភិបាលដែលជាដៃគូនាយកដ្ឋានពេទ្យការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ធ្វើវិភាគរកមេរោគកូវីដ-១៩ ជាប្រចាំសប្តាហ៍ ឬរៀងរាល់ពេល២សប្តាហ៍ ចំពោះ៖

- កម្មករនិយោជិតដែលធ្វើការចល័តពីអគារមួយទៅអគារមួយ
- កម្មករនិយោជិតដែលប្រាស្រ័យទាក់ទងជាមួយបុគ្គលខាងក្រៅ ជាពិសេសបុគ្គលដែលមានប្រវត្តិធ្វើដំណើរទៅក្រៅប្រទេស
- កម្មករនិយោជិតដែលធ្វើការនៅអាហារដ្ឋានរបស់រោងចក្រ
- សន្តិសុខ អ្នកអនាម័យដែលផ្តល់សេវាឆ្លងអគារ ឬរោងចក្រ
- កម្មករនិយោជិតដែលទទួលបន្ទុកបាញ់សម្លាប់មេរោគ និងវាស់កម្តៅ។

រោងចក្រផ្នែកវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប អាចបើកដំណើរការឡើងវិញពេញលេញ ១០០% ប្រសិនជារោងចក្រនោះមានកម្មករនិយោជិតបានចាក់វ៉ាក់សាំងកូវីដ-១៩ដូសទី២ យ៉ាងតិច ៨០% នៃចំនួនកម្មករនិយោជិតសរុប និងប្រសិនជារោងចក្រមានការអនុវត្តត្រឹមត្រូវតាមវិធានសុខាភិបាល វិធានសុវត្ថិភាព និងសុខភាពការងារ និងមានការផ្តល់អាហារថ្ងៃត្រង់ ឬសម្របសម្រួលឱ្យមានការលក់ម្ហូបអាហារប្រកបដោយអនាម័យ និងសុវត្ថិភាពនៅក្នុងបរិវេណរោងចក្រ។

## គ. វិធានការផ្សេងៗ

កម្មករនិយោជិត ដែលមានប្រវត្តិធ្វើដំណើរទៅក្រៅប្រទេស ហើយបានបញ្ចប់ការធ្វើចត្តាឡីស័កចំនួន ១៤ថ្ងៃ គួរបន្តធ្វើចត្តាឡីស័កចំនួន ៧ថ្ងៃ បន្ថែមទៀតនៅផ្ទះ មុននឹងត្រឡប់ចូលមកធ្វើការងារនៅរោងចក្រសហគ្រាសវិញ ឬគួរជ្រើសរើសវិធីសាស្ត្រធ្វើការពីផ្ទះ (តាមអនឡាញ) ចំនួន ៧ថ្ងៃបន្ថែម។

កម្មករនិយោជិតដែលកំពុងព្យាបាលជំងឺកូវីដ-១៩ ឬកំពុងអនុវត្តវិធានការធ្វើចត្តាឡីស័ក ឬស្នាក់នៅក្នុងភូមិសាស្ត្រ ដែលត្រូវបានបិទខ្ទប់ដោយវិធានការរដ្ឋបាលណាមួយ មិនត្រូវបានអនុញ្ញាតឱ្យមកបំពេញការងារនៅក្នុងរោងចក្រ សហគ្រាស ដែលត្រូវបានអនុញ្ញាតឱ្យបើកដំណើរការឡើងវិញនោះទេ។

នៅក្នុងអំឡុងពេលរង់ចាំវេនការងារ កម្មករនិយោជិតមិនត្រូវធ្វើដំណើរទៅទីកន្លែង ដែលកំពុងផ្ទុះវិជ្ជមានកូវីដ-១៩ ឬមានហានិភ័យឆ្លងជំងឺកូវីដ-១៩ នោះទេ និងត្រូវរាយការណ៍អំពីស្ថានភាពសុខភាពរបស់ខ្លួនមករដ្ឋបាលរោងចក្រ សហគ្រាសជាប្រចាំ ព្រមទាំងត្រូវបន្តអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវវិធានការ "៣កុំ" និង "៣ការពារ" និង វិធានការសុខាភិបាលនានា។ ការខកខានមិនបានរាយការណ៍អំពីករណីប៉ះពាល់ផ្ទាល់ជាមួយអ្នកមានវិជ្ជមានកូវីដ-១៩ ឬបានឆ្លងកាត់កន្លែងមានវិជ្ជមានកូវីដ-១៩ ឬអំពីរោគសញ្ញាសង្ស័យនានាឱ្យរដ្ឋបាលរោងចក្រ សហគ្រាស គឺអាចចាត់ទុកថាបានល្មើសនឹងបទបញ្ជាផ្ទៃក្នុងរបស់រោងចក្រ សហគ្រាស និងល្មើសនឹងវិធានសុខាភិបាលសាធារណៈ។

ក្រសួងសង្ឃឹមយ៉ាងមុតមាំថា គ្រប់អង្គភាព ស្ថាប័នពាក់ព័ន្ធ ម្ចាស់ ឬនាយក រោងចក្រ សហគ្រាស និងកម្មករនិយោជិតទាំងអស់នឹងចូលរួមអនុវត្តតាមសេចក្តីណែនាំរួមនេះប្រកបដោយប្រសិទ្ធភាព។

ថ្ងៃព្រហស្បតិ៍ ១០រោច ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ៦ ខែឧសភា ឆ្នាំ២០២១

**រដ្ឋមន្ត្រី**
**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**អ៊ិត សំហេង**

**រដ្ឋមន្ត្រី**
**ក្រសួងសុខាភិបាល**

**ម៉ម ប៊ុនហេង**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

  *"ដើម្បីជូនជ្រាប"*

- គ្រប់រដ្ឋបាលរាជធានី ខេត្ត
- គ្រប់អង្គភាពពាក់ព័ន្ធនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- គ្រប់អង្គភាពពាក់ព័ន្ធនៃក្រសួងសុខាភិបាល
- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី ខេត្ត
- មន្ទីរសុខាភិបាលរាជធានី ខេត្ត

  *"ដើម្បីសហការអនុវត្ត"*

- ឯកសារ កាលប្បវត្តិ

# គំរូលិខិតវាយតម្លៃរបស់ក្រុមការងារបច្ចេកទេសចម្រុះ

ឈ្មោះរោងចក្រ សហគ្រាស៖.......................................................

អាសយដ្ឋាន៖.......................................................

លេខទូរស័ព្ទ៖.......................................................

| ល.រ | លក្ខណៈវិនិច្ឆ័យ | លទ្ធផល |
|---|---|---|
| ១ | ចំនួនអគារ ឬចំនួនជាន់នៃអគាររបស់រោងចក្រ សហគ្រាស | |
| ២ | ចំនួនករណីវិជ្ជមានកូវីដ-១៩ | |
| ៣ | ដឹងប្រភពនៃការឆ្លងឬទេ? | |
| ៤ | អាចស្វែងរកអ្នកប៉ះពាល់ផ្ទាល់ឬទេ? ចំនួនប៉ុន្មាន? | |
| ៥ | អាចស្វែងរកអ្នកប៉ះពាល់ប្រយោលឬទេ? ចំនួនប៉ុន្មាន? | |
| ៦ | អ្នកវិជ្ជមានជួប ឬធ្វើដំណើរឆ្លងកម្មករនិយោជិតនៅអគារផ្សេងញឹកញាប់ឬទេ? | |
| ៧ | មានច្រកចេញចូលអគារអាជីវកម្ម/ផលិតកម្មប៉ុន្មាន? សមរម្យឬទេ? | |
| ៨ | មានជណ្ដើររួមប៉ុន្មាន? ទំហំសមរម្យសម្រាប់ឡើងចុះឬទេ? | |
| ៩ | មានប្រព័ន្ធខ្យល់ចេញ-ចូលគ្រប់គ្រាន់ឬទេ? | |
| ១០ | មានការបាញ់អាល់កុល និងវាស់កម្ដៅមុនចូលធ្វើការឬទេ? | |
| ១១ | មានកន្លែងលាងសម្អាតដៃ និងបន្ទប់ទឹកសមរម្យឬទេ? | |
| ១២ | មានសាប៊ូលាងដៃ ឬអាល់កុលគ្រប់គ្រាន់នៅកន្លែងលាងសម្អាតដៃ និងបន្ទប់ទឹកឬទេ? | |
| ១៣ | មានផ្ដល់ម៉ាសជូនកម្មករនិយោជិតឬទេ? | |
| ១៤ | មានធុងសម្រាមច្រើនអាចដាក់សម្រាម និងការផ្លាស់ប្ដូរម៉ាសគ្រប់គ្រាន់ឬទេ? | |
| ១៥ | មានការបាញ់សម្លាប់មេរោគក្នុងអគារឬទេ? | |
| ១៦ | ការរៀបចំកន្លែងអង្គុយធ្វើការទល់មុខគ្នា ឬស្របគ្នា ឬបែរខ្នងរកគ្នា? | |
| ១៧ | គម្លាតប៉ាន់ស្មាននៃការអង្គុយរបស់កម្មករនិយោជិត | |
| ១៨ | មានផ្ដល់អាហារថ្ងៃត្រង់ជូនកម្មករនិយោជិតឬទេ? | |
| ១៩ | មានអាហារដ្ឋានឬទេ? | |
| ២០ | អាហារដ្ឋានអាចផ្ទុកមនុស្សបានប៉ុន្មានក្នុងពេលតែមួយ? | |

| | | |
|---|---|---|
| ២១ | ចែកចេញជាប៉ុន្មានវេនបាយ? | |
| ២២ | គម្លាតប៉ាន់ស្មានពេលហូបបាយ? | |
| ២៣ | មានកម្មករនិយោជិតជិះរថយន្តរួមគ្នាមកធ្វើការចំនួនប៉ុន្មាននាក់? | |
| ២៤ | ភូមិកំណើតរបស់កម្មករនិយោជិតដែលជិះយានយន្តរួមគ្នាមានវិជ្ជមានកូវីដ-១៩ ឬជាតំបន់មានហានិភ័យឬទេ? | |
| ២៥ | មានកម្មករនិយោជិតចំនួនប៉ុន្មានស្នាក់នៅតាមផ្ទះជួលរួមគ្នា? | |
| ២៦ | ប្លុកផ្ទះជួលរបស់កម្មករនិយោជិតមានវិជ្ជមានកូវីដ-១៩ ឬទេ ឬជាតំបន់មានហានិភ័យឬទេ? | |
| ២៧ | មានគ្រូពេទ្យប្រចាំរោងចក្រ ឬសហគ្រាសឬទេ? | |
| ២៨ | មានអ្នកទទួលខុសត្រូវតាមដានវិធានសុខាភិបាល និងសុវត្ថិភាពនិងសុខភាពការងារឬទេ? | |
| ២៩ | មានផ្ទាំងផ្សព្វផ្សាយ ឬណែនាំអំពីវិធានសុខាភិបាលឬទេ? | |
| ៣០ | មានប្រព័ន្ធបំពងសម្លេងឬទេ? បានចាក់សម្លេងផ្សព្វផ្សាយអំពីវិធានសុខាភិបាលឬទេ? | |
| ៣១ | មានកម្មករនិយោជិតបរទេសសរុបចំនួនប៉ុន្មាននាក់? | |
| ៣២ | មានការសហការល្អជាមួយអាជ្ញាធរមានសមត្ថកិច្ច និងក្រុមការងារបច្ចេកទេសចម្រុះឬទេ? | |
| ៣៣ | បានបំពេញតាមសំណូមពរ ឬបានកែលម្អភ្លាមៗតាមមន្ត្រីមានសមត្ថកិច្ច និងមន្ត្រីសុខាភិបាលឬទេ? | |

*ការវាយតម្លៃរួម៖*........................................................................................................................................................................................

*រយៈពេលនៃការផ្អាក៖ ចំនួន ថ្ងៃ កាលបរិច្ឆេទដែលត្រូវបើកដំណើរការឡើងវិញ៖*

ថ្ងៃទី ខែ ឆ្នាំ២០២១

| តំណាងរោងចក្រសហគ្រាស | តំណាងក្រសួង/មន្ទីរសុខាភិបាល | តំណាងរដ្ឋបាលរាជធានី ខេត្ត | តំណាងក្រសួង/មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
|---|---|---|---|
| ឈ្មោះ | ឈ្មោះ | ឈ្មោះ | ឈ្មោះ |
| Tel:.......................... | Tel:.......................... | Tel:.......................... | Tel:.......................... |